ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី២៥ ខែមីនា ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# កិច្ចប្រជុំស្តីអំពី
# លទ្ធផលប្រមូលចំណូលពន្ធប្រចាំត្រីមាសទី១ ឆ្នាំ២០១៤

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤ នៅអគ្គនាយកដ្ឋានពន្ធដារ បានបើកកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលពន្ធប្រចាំត្រីមាសទី១ ឆ្នាំ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **ជុំ វិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានវត្តមានចូលរួមពីសំណាក់ឯកឧត្តមអគ្គនាយករង លោកប្រធាន-អនុប្រធាននាយកដ្ឋានថ្នាក់កណ្តាល ប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ ។










កិច្ចចាប់ផ្តើម ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រីបានវាយតម្លៃខ្ពស់ និងអបអរសាទរចំពោះលទ្ធផលនៃការខិតខំប្រឹងប្រែង របស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជាមន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ ក្នុងការប្រមូលចំណូលពន្ធ-អាករ គ្រប់ប្រភេទសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៤ ។ ជាលទ្ធផលការប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទសម្រាប់ត្រីមាសទី១ ដើមឆ្នាំ២០១៤ គិតត្រឹមសប្តាហ៍ទីបីនៃខែមីនា អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលបានចំនួន **៧៦៧.៧៧៤,០២ លានរៀល** (គិតជាដុល្លារ **១៩១,៩៤ លានដុល្លារ**) គឺស្មើនឹង **១៩,៣១%** នៃផែនការកំណត់ដោយច្បាប់ ។ ដោយរដូវកាលនៃការប្រកាសបង់ពន្ធលើប្រាក់ចំណេញនៅមិនទាន់បានបិទបញ្ចប់នៅឡើយ អគ្គនាយកដ្ឋានពន្ធដាររំពឹងថាចំណូលពន្ធនឹងមានការកើនឡើងនៅក្រោយការបិទបញ្ចប់នៃការប្រមូលពន្ធលើប្រាក់ចំណេញ នាដំណាច់ខែមីនានេះ ។

ក្នុងរយៈពេលចុងក្រោយនេះ អគ្គនាយកដ្ឋានពន្ធដារបានចាប់យករបត់នៃការកែទម្រង់ថ្មីមួយ ដែលធ្វើឲ្យស្ថានភាពនៃការពង្រឹងរដ្ឋបាលសារពើពន្ធ និងគោលនយោបាយសារពើពន្ធ ត្រូវបានផ្លាស់ប្តូរផងដែរ ។ ស្ថិតក្នុងបរិបទនេះ ការរៀបចំ

ធ្វើវិសោធនកម្មច្បាប់ស្តីពីពន្ធដារ ព្រមទាំងការរៀបចំបង្កើតនិងបំពេញបន្ថែមនូវរាល់លិខិតបទដ្ឋានគតិយុត្តនានា ត្រូវបានធ្វើឡើង ក្នុងបំណងធ្វើយ៉ាងណាឲ្យនីតិវិធីនៃការប្រមូលពន្ធប្រព្រឹត្តទៅដោយរលូន ប្រកបដោយតម្លាភាព ប្រសិទ្ធភាពខ្ពស់ និងការបង្កើតនូវបរិយាកាសប្រកួតប្រជែងដោយស្មើភាពគ្នាចំពោះគ្រប់ធុរជន ។ ទង្វើករណ៍សំខាន់ៗដែលជាលទ្ធផលនៃរបត់កំណែទម្រង់ ជាពិសេស ក្នុងរយៈពេលបីខែ ដើមឆ្នាំ២០១៤ នេះ បានស្តែងចេញឲ្យឃើញតាមរយៈលទ្ធផលការងារសំខាន់ៗដូចខាងក្រោម ÷

I- **ការកែលំអរដ្ឋបាលសារពើពន្ធ**

- បង្កើតមជ្ឈមណ្ឌលរក្សាទុកទិន្នន័យ (Data Center) ដោយសម្រេចបានប្រមាណជា ៩០% ហើយ ។ ការបង្កើតនូវមជ្ឈមណ្ឌលរក្សាទុកទិន្នន័យនេះឡើង គឺដើម្បីប្រមូលរាល់ឯកសាររបស់អ្នកជាប់ពន្ធពីបណ្តាគ្រប់សាខាពន្ធដារខេត្ត-ខណ្ឌ ដើម្បីយកមករក្សាទុកនៅទីនេះ និងដើម្បីងាយស្រួលក្នុងការស្វែងរក ។
- បានរៀបចំបង្កើត Call Center ដើម្បីឆ្លើយតបនូវរាល់ចម្ងល់របស់អ្នកជាប់ពន្ធដែលសាកសួរមកអគ្គនាយកដ្ឋាន ។
- រៀបចំធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីងាយស្រួលគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធ ក្នុងនោះបាននិងកំពុងរៀបចំការដាក់លិខិតប្រកាសពន្ធ និងបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិច (E-Filing និង E-payment) ដោយសហការជាមួយក្រុមហ៊ុន Wing និងជាមួយធនាគារមួយចំនួនដែលបានចុះកិច្ចព្រមព្រៀងអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនដើម្បីស្នើសុំទិន្នន័យពាក់ព័ន្ធនឹងការប្រមូលចំណូលពន្ធ សម្រាប់ជាប្រយោជន៍ក្នុងការផ្ទៀងផ្ទាត់ការបង់ពន្ធរបស់អ្នកជាប់ពន្ធ ។
- ចេញសេចក្តីជូនដំណឹងស្តីពីការរំលឹកការបង់ពន្ធលើអចលនទ្រព្យ និងការចុះត្រួតពិនិត្យលើអចលនទ្រព្យដែលមិនទាន់ប្រកាសបង់ពន្ធ និងការរំលឹកការបង់ពន្ធផ្សេងៗទៀតជាបន្តបន្ទាប់ ព្រមទាំងរៀបចំចុះត្រួតពិនិត្យការអនុវត្តការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ និងពន្ធលើអចលនទ្រព្យផងដែរ ។
- បានរៀបចំកែសម្រួលដំណើរការនៃសង្វាក់ផលិតកម្មការងារ (Business Process) នៃការដាក់លិខិតប្រកាសបង់ពន្ធរបស់អ្នកជាប់ពន្ធ ដោយកាត់បន្ថយនីតិវិធីនៃការបង់ប្រាក់ពន្ធ ដោយតម្រូវឲ្យអ្នកជាប់ពន្ធគ្រាន់តែមកយកលិខិតស្នើបង់ប្រាក់ពន្ធ ហើយបន្ទាប់មក ទៅបង់ប្រាក់ពន្ធនៅធនាគារ ជាការស្រេច ។
- បានរៀបចំដំណើរការប្រព័ន្ធជូនដំណឹងដល់អ្នកជាប់ពន្ធ (Notification System) ដើម្បីរំលឹកអ្នកជាប់ពន្ធឲ្យមកប្រកាសបង់ពន្ធបានទាន់ពេលវេលា ដោយបានដាក់ឲ្យប្រើប្រាស់សាកល្បងក្នុងដំណាក់កាលដំបូងនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ។
- ធ្វើបច្ចុប្បន្នភាពការចុះបញ្ជីក្រុមហ៊ុនដែលត្រូវជាប់អាករលើតម្លៃបន្ថែម ដើម្បីឲ្យមានសុវត្ថិភាព និងគ្រប់គ្រងឲ្យបានប្រសើរជាងមុន ដោយបានបោះពុម្ពជាថ្មីឡើងវិញនូវសន្លឹកវិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (VAT Certificate) សន្លឹកបណ្ណប៉ាតង់ លិខិតបញ្ជាក់ពីការបំពេញកាតព្វកិច្ចសារពើពន្ធ និងលិខិតបញ្ជាក់ពីស្ថានភាពសារពើពន្ធ ព្រមទាំងគ្រោងដាក់ឲ្យប្រើប្រាស់នៅដើមត្រីមាសទី២ នៃឆ្នាំ២០១៤ ។
- ផ្ទេរអាជីវកម្មបង់ពន្ធតាមរបបម៉ៅការដែលមានផលរបរខ្ពស់ ទៅជារបបស្វ័យប្រកាស ដោយដាក់ផែនការចាត់បញ្ចូលឲ្យបាន ២០% នៃអាជីវកម្មដ្ឋានដែលស្ថិតក្នុងរដ្ឋបាល ដែនដីនៃខេត្ត-ខណ្ឌនីមួយៗ ។
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីប្រព័ន្ធពន្ធដារកម្ពុជា និងប្រភេទពន្ធផ្សេងៗ ព្រមទាំងកំពុងរៀបចំជា Spots អប់រំខ្លីៗ ដើម្បីចាក់ផ្សាយតាមកញ្ចក់ទូរទស្សន៍ និងបានរៀបចំសៀវភៅណែនាំ (Booklet) ស្តីពីពន្ធប៉ាតង់ ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអចលនទ្រព្យ ។
- បានពង្រឹងមុខងារភារកិច្ចរបស់សាលាជាតិពន្ធដារ ដោយបានរៀបចំកែលំអផែនការកម្មវិធីបណ្តុះបណ្តាល និងផលិតឯកសារសម្រាប់វគ្គបណ្តុះបណ្តាល ។

- ចាត់វិធានការច្បាប់ជាបន្ទាន់និងជាបន្តបន្ទាប់ ចំពោះសហគ្រាសរឹងរូសដែលមិនគោរពច្បាប់ស្តីពីសារពើពន្ធ ដើម្បីឱ្យចូលខ្លួនមកពិភាក្សាអំពីកាតព្វកិច្ចសារពើពន្ធ និងដោះស្រាយបញ្ហាបំណុលពន្ធ ។
- បង្កើតក្រុមការងារពិសេសដែលមានភារកិច្ចប្រើប្រាស់គ្រប់រូបភាព ដើម្បីស្រាវជ្រាវប្រមូលផ្តុំព័ត៌មានស្តីពីការគេចវេះពន្ធ លួចបន្លំពន្ធរបស់សហគ្រាសមួយចំនួនធំ ជាពិសេសសហគ្រាសនាំចេញ-ចូល លក់ទំនិញ ផ្គត់ផ្គង់សេវា ។
- អប់រំណែនាំដល់មន្ត្រីគ្រប់លំដាប់ថ្នាក់ឱ្យធ្វើការផ្លាស់ប្តូរឥរិយាបថ ផ្នត់គំនិត (Mindset) ក្នុងការបម្រើសេវាជូនអ្នកជាប់ពន្ធ ដោយមិនត្រូវប្រើពាក្យគំរោះគំរើយ តែត្រូវញញឹមញញែម ទន់ភ្លន់ និងត្រូវគោរពវិន័យការងារ ក្រមសីលធម៌វិជ្ជាជីវៈ បំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់ ពោលគឺត្រូវម៉ឺងម៉ាត់ខាងទិដ្ឋភាពច្បាប់ ក្នុងការឆ្លើយតបទៅកាន់អ្នកជាប់ពន្ធ ។

## II- **ការកែលំអគោលនយោបាយសារពើពន្ធ**

ក្នុងឋានៈជាស្ថាប័នដ៏មានសារៈសំខាន់ជាសារវន្តរបស់ប្រទេស អគ្គនាយកដ្ឋានពន្ធដារបានកែសម្រួលគោលនយោបាយសារពើពន្ធមួយចំនួន ដើម្បីឆ្លើយតបនឹងសភាពការណ៍ជាក់ស្តែង ៖

- រៀបចំវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ ឱ្យស្របតាមស្ថានភាពរីកចំរើននៃសេដ្ឋកិច្ចជាតិ និងដើម្បីឱ្យមានសង្គតិភាពជាមួយនឹងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងច្បាប់នានាដែលពាក់ព័ន្ធ ។
- បានធ្វើបច្ចុប្បន្នភាពគណៈកម្មការកំណែទម្រង់ច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ សម្រាប់ការរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិសារពើពន្ធនានា ។
- បានបញ្ចប់បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត រ៉ែ និងឧស្ម័នធម្មជាតិ ដើម្បីបញ្ចូលទៅក្នុងច្បាប់ស្តីអំពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ ។
- បញ្ចប់សេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Tax Agreement) គំរូកម្ពុជា និងកំពុងរៀបចំក្រុមការងារ ព្រមទាំងកំណត់ប្រទេសសម្រាប់កិច្ចចរចា នៅក្នុងឆ្នាំ២០១៤ ។
- រៀបចំប្រកាសស្តីពីការផ្ទេរថ្លៃ (Transfer Pricing) ដែលកិច្ចការនេះ ស្ទើតែបញ្ចប់ទាំងស្រុងទៅហើយ ។
- បានកែសម្រួលលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងអាករលើតម្លៃបន្ថែម ដោយបានចេញជាប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមលើការនាំចូល និងការផ្គត់ផ្គង់ទំនិញមួយចំនួន, ប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យាដែលផ្គត់ផ្គង់ទំនិញឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបដៃ និងឧស្សាហកម្មផលិតមួក, ប្រកាសស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះអ្នកចុះកិច្ចសន្យាដែលធ្វើការផ្គត់ផ្គង់អង្ករ សម្រាប់បម្រើឱ្យការនាំចេញអង្ករ ។
- បានរៀបចំកែសម្រួលអនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានា ទាក់ទងនឹងអាករពិសេសលើទំនិញ និងសេវាមួយចំនួន ដោយធ្វើការកែសម្រួលមូលដ្ឋាន និងអត្រាគិតអាករពិសេស ។
- បានរៀបចំដាក់មន្ត្រីឱ្យប្រចាំការនៅតាមរោងចក្រដែលផលិតផលិតផលត្រូវជាប់អាករពិសេសក្នុងស្រុក ដើម្បីធ្វើការកត់ត្រារាល់ប្រតិបត្តិការបញ្ចេញទំនិញរបស់ក្រុមហ៊ុន ។
- បានបញ្ចប់ឧបសម្ព័ន្ធភ្ជាប់ស្តីពីតម្លៃអចលនទ្រព្យសម្រាប់ពន្ធប្រថាប់ត្រា ដែលនេះមិនធ្លាប់មានទាល់តែសោះ ពីមុនមក និងត្រៀមរៀបចំប្រកាសស្តីពីតម្លៃអចលនទ្រព្យសម្រាប់ពន្ធប្រថាប់ត្រា ។
- ពង្រឹង និងរៀបចំយន្តការទារបំណុលពន្ធ ដោយបានរៀបចំប្រកាសស្តីពីការទូទាត់បំណុលពន្ធ តាមរយៈកិច្ចព្រមព្រៀងទូទាត់ជាដំណាក់កាល និងកែសម្រួលប្រកាសស្តីពីវិធាន និងនីតិវិធីចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធមិនអាចប្រមូលបាននាពេលបច្ចុប្បន្ន ។

- កំពុងរៀបចំប្រកាសអន្តរក្រសួងស្តីពីការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ជូនមន្ត្រីពន្ធដារ ដើម្បីឱ្យមន្ត្រីពន្ធដារមានលទ្ធភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ ក្នុងការស្រាវជ្រាវ និងអង្កេតបទល្មើសពន្ធដារ ព្រមទាំងឃាត់ទុករាល់ទំនិញ ឬឃាត់ខ្លួនអ្នកជាប់ពន្ធដែលមិនគោរពច្បាប់ស្តីពីសារពើពន្ធ ។

ដើម្បីធានាបាននូវការប្រមូលចំណូលគ្រប់តាមផែនការកំណត់ដោយច្បាប់ ក៏ដូចជាតាមភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ជូន ឯកឧត្តមរដ្ឋមន្ត្រីបានផ្តល់នូវអនុសាសន៍ណែនាំសម្រាប់ជាការចង្អុលបង្ហាញក្នុងការអនុវត្តការងារ ដូចខាងក្រោម ÷

- បន្តពង្រឹងការកែលំអការផ្តល់សេវាជូនអ្នកជាប់ពន្ធ ។ ទន្ទឹមនឹងនេះ ក៏ត្រូវកែលំអការគ្រប់គ្រងអ្នកជាប់ពន្ធឱ្យបានល្អប្រសើរជាងមុន ប្រកបដោយតម្លាភាព និងគណនេយ្យភាព ដែលក្នុងនោះ ត្រូវបន្តអនុវត្តឱ្យបានចប់សព្វគ្រប់នូវរាល់គម្រោងធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ក្នុងន័យធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធរដ្ឋបាលសារពើពន្ធ និងការគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធ ។
- បន្តរៀបចំកម្មវិធីផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ និងសារព័ត៌មាននានា ដោយបង្កើតជា Spots អប់រំ ឬជាឯកសាររូបភាពខ្លីៗ ឬសេចក្តីប្រកាសព័ត៌មាន ជាដើម ដោយមិនត្រឹមតែពន្យល់ណែនាំដល់អ្នកជាប់ពន្ធនូវប្រភេទពន្ធនីមួយៗប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវពន្យល់ពីនីតិវិធីនៃការបង់ពន្ធ ការកែទម្រង់ និងអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ផងដែរ ។ ផ្តើមចេញពីនេះ ត្រូវរៀបចំបង្កើតក្រុមការងារមួយដែលអាចជួយប្រតិភូរាជរដ្ឋាភិបាល ក្នុងការតាមដានកិច្ចការងារសាធារណៈ ដូចជាតាមដានសារព័ត៌មាន ឬសេវាព័ត៌មានតាមទូរទស្សន៍នានា ដើម្បីឱ្យដឹងថាតើមានការលើកឡើងអ្វីខ្លះដែលទាក់ទងនឹងពន្ធដារ ។
- រៀបចំបណ្តុះបណ្តាល កសាងសមត្ថភាពមន្ត្រីពន្ធដារជាខ្សែសង្វាក់ តាមរយៈការប្រើប្រាស់ធនធានដែលយើងមានស្រាប់ នោះគឺសាលាជាតិពន្ធដារ ឬត្រូវអញ្ជើញអ្នកជំនាញមកធ្វើបទបង្ហាញ ។ ព្រមជាមួយនោះ ត្រូវពិនិត្យលទ្ធភាពក្នុងការបញ្ជូនថ្នាក់ដឹកនាំសំខាន់ៗរាប់តាំងពីប្រធានការិយាល័យឡើងទៅ ដើម្បីទទួលបានការបណ្តុះបណ្តាលនៅបរទេស ។
- ជំរុញបន្តអនុវត្តតាមផែនការសកម្មភាពការងារដែលបានដាក់ជូន**សម្តេចតេជោ** និងក្រសួងពិនិត្យសម្រេចកន្លងនាពេលមក ឱ្យបានដូចភ្លៀងរលឹម ។ ទន្ទឹមនឹងនេះ ត្រូវរៀបចំផែនការសកម្មភាពដើម្បីឆ្លើយតបនឹងអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ។
- ជំរុញល្បឿននៃការរៀបចំយុទ្ធសាស្ត្រកៀរគរចំណូលពន្ធឱ្យបានចប់សព្វគ្រប់ និងបានគ្រប់ជ្រុងជ្រោយ ព្រោះថានេះគឺជាត្រីវិស័យ ឬជាគោលចរ សម្រាប់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការប្រមូលចំណូលពន្ធ ។
- បន្តធ្វើការងារជាមួយវិស័យឯកជន ក្នុងក្របខ័ណ្ឌក្រុមការងារ “ឃ” រវាងអគ្គនាយកដ្ឋានពន្ធដារ និងវិស័យឯកជនដោយបន្តពិភាក្សាគ្នាលើចំណុចមួយចំនួនទៀតដែលមិនទាន់ដោះស្រាយនៅឡើយ ដែលការពិភាក្សានេះត្រូវឈរលើស្មារតីបើកចំហក្នុងន័យស្ថាបនា ។
- ជំរុញល្បឿននៃការរៀបចំក្រុមការងារចរចា ការចៀសវាងការយកពន្ធត្រួតគ្នា (DTA) ដោយត្រូវរៀបចំបង្កើតក្រុមការងារជាពីរកម្រិតគឺ ÷ កម្រិតគោលនយោបាយ ដែលមានសមាសភាពថ្នាក់ដឹកនាំក្រសួង និងថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធ និងក្រុមការងារកម្រិតបច្ចេកទេស ដែលមានអគ្គនាយកដ្ឋានពន្ធដារជាអ្នកដឹកនាំផ្ទាល់ ។ បន្ទាប់មក ត្រូវរៀបចំកម្មវិធីចរចាដោយជ្រើសរើសប្រទេសណាមួយក្នុងបណ្តាប្រទេសសមាជិកអាស៊ាន ជាអាទិភាព ។
- ព្រមជាមួយនេះដែរ ត្រូវជំរុញល្បឿនពិភាក្សាក្រុមការងារស្តីពីអនុលោមភាពពន្ធចំពោះគណនេយ្យក្រៅប្រទេសរបស់អាមេរិក (Foreign Account Tax Compliance Act - FATCA) ដោយហេតុថា កិច្ចព្រមព្រៀង FATCA នេះនឹងចូលជាធរមាននៅក្នុងខែមិថុនា ឆ្នាំ២០១៤ ខាងមុខនេះ ដូច្នេះត្រូវខិតខំជំរុញកិច្ចការនេះឱ្យបានឆាប់ ។
- បន្តជំរុញបញ្ចប់បទប្បញ្ញត្តិ និងសេចក្តីព្រាងប្រកាសពន្ធលើប្រតិបត្តិការប្រេងកាត និងបទប្បញ្ញត្តិស្តីពីប្រតិបត្តិការធនធានរ៉ែ ។
- បន្តជំរុញកិច្ចការគោលនយោបាយផ្ទេរអ្នកជាប់ពន្ធពីរបបម៉ៅការ ទៅរបបស្វ័យប្រកាសឱ្យបានជាអតិបរមា មុននឹងឈានទៅរកគោលការណ៍លុបបំបាត់ចោលការបង់ពន្ធតាមរបបម៉ៅការ ។

ជាទីបញ្ចប់ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ បានវាយតម្លៃខ្ពស់ចំពោះគ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលដែលមានការកើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់មន្ត្រី ពន្ធដារគ្រប់លំដាប់ថ្នាក់ ឲ្យខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈឲ្យបានត្រឹមត្រូវ និងត្រូវមានភាពទន់ភ្លន់ តែម៉ឺងម៉ាត់ដោយផ្អែកទិដ្ឋភាពច្បាប់ជាមូលដ្ឋាន ក្នុងការឆ្លើយតបទៅកាន់អ្នកជាប់ពន្ធ ដោយធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធសប្បាយចិត្ត មិនសម្តែងការរអ៊ូរទាំ និងផ្តល់កិច្ចសហការល្អ ក្នុងការបង់ពន្ធជូនរដ្ឋ ។


រូបភាព៖ ដោយអគ្គនាយកដ្ឋានពន្ធដារ ២០១៤


រូបភាព៖ ដោយអគ្គនាយកដ្ឋានពន្ធដារ ២០១៤

**អគ្គនាយកដ្ឋានពន្ធដារ**